## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តពោធិ៍សាត់**

លេខ...០៤៣/១៦...សជណ/ខពស

ពោធិ៍សាត់ ថ្ងៃទី...១៩......ខែ...កញ្ញា...ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង
## ស្តីពីការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៧

អភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៧ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៧។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការមានសិទ្ធិដាក់សំណើដេញថ្លៃគ្រប់គម្រោងមូលនិធិឃុំ សង្កាត់ ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**អ្នកទទួលការសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធត្រូវបានបែងចែកជា០៣ប្រភេទ ៖**

- ប្រភេទទី១ ៖ អ្នកទទួលការសំណង់ទូទៅ (ការងារសំណង់អគារ និងការងារបេតុង ... ។ល។)
- ប្រភេទទី២ ៖ អ្នកទទួលការការងារដី (ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រួសក្រហម លូមូល ទ្វារទឹកខ្នាតតូច ... ។ល។)
- ប្រភេទទី៣ ៖ អ្នកទទួលការឯកទេស (អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារពិសេស ឧទាហរណ៍អណ្តូងស្នប់ ... ។ល។)

**អ្នកទទួលការសម្រាប់គម្រោងសេវាកម្មត្រូវបានបែងចែកជា០៣ប្រភេទ ៖**

- ប្រភេទទី១ ៖ អ្នកផ្តល់សេវារៀបចំសហគមន៍ (ជលផល ព្រៃឈើ ទេសចរណ៍ ធម្មជាតិអភិរក្ស.... ។ល។)
- ប្រភេទទី២ ៖ អ្នកផ្តល់សេវាបច្ចេកទេសកសិកម្ម (ការដាំដុះដំណាំ ការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី.... ។ល។)
- ប្រភេទទី៣ ៖ អ្នកផ្តល់សេវាសិប្បកម្ម (ត្បាញកន្ទេល កែច្នៃអនុផលព្រៃឈើ កែច្នៃចំណីអាហារ.... ។ល។)

អ្នកទទួលការ អ្នកផ្តល់សេវា ត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារៈបរិក្ខារគ្រប់គ្រាន់ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ ហើយត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទងនឹងប្រភេទនីមួយៗដែលបានស្នើសុំយ៉ាងតិច០២ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ។ អនុគណៈកម្មការបុរេលក្ខណសម្បត្តិនឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការជាមួយម្ចាស់គម្រោងដោយផ្អែកលើកំណត់ត្រាកន្លងមក។ លទ្ធផលនៃការវាយតម្លៃនេះ អនុគណៈកម្មការបុរេលក្ខណសម្បត្តិនឹងដាក់ជូនអភិបាលនៃគណៈអភិបាលខេត្ត ដើម្បីពិនិត្យនិងសម្រេច។ អ្នកទទួលការ និងអ្នកផ្តល់សេវាទាំងឡាយណា ដែលត្រូវបានរកឃើញថាមានការពាក់ព័ន្ធ នឹងការឃុបឃិតស៊ុំគ្រលំគ្នា ការក្លែងបន្លំ និងអំពើពុករលួយ ហើយចាប់ពីពេលដែលត្រូវបានដកសិទ្ធិជាផ្លូវការ អ្នកទទួលការនោះនឹងមិនត្រូវបាន ពិចារណាក្នុងការបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ។

អាស្រ័យហេតុនេះ បើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ សូមរួសរាន់មកដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ នៅទីចាត់ការផែនការ និងវិនិយោគនៃសាលាខេត្តពោធិ៍សាត់ ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ១៧.០០។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមកក៏ត្រូវដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មីឡើងវិញដែរ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅទីចាត់ការផែនការ និងវិនិយោគដោយឥតបង់ថ្លៃ តាមអាសយដ្ឋានក្នុងបរិវេណសាលាខេត្ត ឬអាចទាញយកពីក្នុងគេហទំព័ររបស់ គ.ជ.អ.ប(www.ncdd.gov.kh)។

**អភិបាលនៃគណៈអភិបាលខេត្ត**

**ម៉ៅ_ធនិន**

សាលាខេត្តពោធិ៍សាត់ ភូមិពាលញែក II សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ទូរស័ព្ទ: ០១២ ៨២២ ៨៤៧/ ០៥២ ៧៤៦ ៩៩៩ ទូរសារ: ០៥២ ៧៤៥ ៩៩៩

Email : pursat.info@gmail.com